# ជំនឿតៗគ្នា និងការពិតនៃថ្នាំបង្ការជំងឺ COVID-19

ការដែលមនុស្សគ្រប់គ្នាទទួលបានព័ត៌មានផ្នែកសុខភាពដែលច្បាស់លាស់នោះគឺជាការសំខាន់ ដូច្នេះពួកគេអាចធ្វើការសម្រេចចិត្តដ៏ល្អបំផុតសម្រាប់ខ្លួនពួកគេ និងក្រុមគ្រួសាររបស់ពួកគេ អំពីថ្នាំបង្ការជំងឺ COVID-19។ ការបែងចែកនូវអ្វីដែលជាព័ត៌មានពិត និងអ្វីដែលមិនពិតនោះគឺមិនមែនជាការងាយស្រួលគ្រប់ពេលនោះទេ។ ព័ត៌មានច្បាស់លាស់អំពីថ្នាំបង្ការមានសារៈសំខាន់ណាស់ ហើយអាចជួយបញ្ឈប់ជំនឿតៗគ្នា និងពាក្យចចាមអារាមទាំងឡាយបាន។

ប្រសិនបើអ្នកកំពុងគិតគូរអំពីការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ឬកំពុងជួយមិត្តភក្តិដែលមិនសូវយល់ច្បាស់នោះ សូមចូលមើល ប្រភពដែលគួរឱ្យទុកចិត្ត ទាំងនេះ សម្រាប់ព័ត៌មានអំពីថ្នាំបង្ការដែលច្បាស់លាស់ និងសូមមើលព័ត៌មានការពិតទាំងឡាយខាងក្រោម៖

**ជំនឿតៗគ្នា #1៖ ថ្នាំបង្ការត្រូវបានបង្កើតឡើងយ៉ាងឆាប់រហ័សពេក ហើយពួកគេមិនដឹងថាតើថ្នាំបង្ការទាំងនេះមានសុវត្ថិភាព ឬអត់នោះទេ។**

**ការពិត៖ ថ្នាំបង្ការទាំងនេះអាចមានការផលិតឡើងយ៉ាងឆាប់រហ័ស ហើយនៅតែមានសុវត្ថិភាពដោយសារហេតុផលជាច្រើន។**

- អ្នកវិទ្យាសាស្ត្របានចាប់ផ្តើមរួចជាស្រេចខ្លះហើយ ដោយសារពួកគេបានសិក្សាអំពីមេរោគកូរ៉ូណាផ្សេងទៀតដូចជារោគសញ្ញាផ្លូវដង្ហើមខ្លាំងនិងធ្ងន់ធ្ងរ (SARS) និងរោគសញ្ញាផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS) រួចមកហើយ។ ពួកគេក៏បានសិក្សាអំពីថ្នាំបង្ការប្រភេទភ្នាក់ងារ RNA (mRNA) ថ្នាំបង្ការប្រភេទដឹកជញ្ជូន (viral vector) និងថ្នាំបង្ការប្រភេទបំណែកនៃជាតិប្រូតេអ៊ីន (subunit protein) ផងដែរ។ ទាំងនេះគឺជាប្រភេទថ្នាំបង្ការជំងឺ COVID-19 ដែលមានការប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក។
- រដ្ឋាភិបាលបានផ្តល់ថវិកា និងធនធានជាច្រើនសម្រាប់ការបង្កើតថ្នាំបង្ការ។ ការធ្វើដូចនេះបានធ្វើឱ្យអ្នកវិទ្យាសាស្ត្រនានាមានភាពងាយស្រួលក្នុងការសហការគ្នា។
- អ្នកស្រាវជ្រាវបានប្រើប្រាស់បណ្តាញទំនាក់ទំនងជាច្រើនដែលមានស្រាប់ ដើម្បីធ្វើការសាកល្បងថ្នាំបង្ការជំងឺ COVID-19។ ការសាកល្បងអាចចាប់ផ្តើមបានយ៉ាងឆាប់រហ័ស ពីព្រោះមានមនុស្សដែលមានចិត្តចង់ចូលរួមក្នុងការសាកល្បងទាំងនេះ។
- រដ្ឋបាលចំណីអាហារនិងឱសថ (FDA) ហើយនិងមជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) បានផ្តល់អាទិភាពដល់ការពិនិត្យឡើងវិញ និងការផ្តល់សិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ។
- មានការអនុវត្តន៍ដំណាក់កាលខ្លះដើម្បីបង្កើតនិងផលិតថ្នាំបង្ការ ក្នុងពេលតែមួយ ជាជាងការធ្វើមួយដំណាក់កាលម្តងៗ។ ឧទាហរណ៍ ការផលិតបានចាប់ផ្តើមខណៈពេលដែលការសាកល្បងថ្នាំបង្ការកំពុងតែមានការដំណើរការ។ អ្វីដែលសំខាន់គឺថា រាល់ជំហានដែលត្រូវតែអនុវត្តតាមដើម្បីផលិតថ្នាំបង្ការថ្មី និងត្រូវតែប្រាកដថាមានសុវត្ថិភាពនោះ គឺមានការអនុវត្តន៍តាម។

**រហូតមកដល់ពេលនេះ មានការផ្តល់ជូនថ្នាំបង្ការជំងឺ COVID-19 ច្រើនជាង 619 លានដូសនៅក្នុងសហរដ្ឋអាមេរិក។ បើទោះបីជាផលប៉ះពាល់កម្រិតធ្ងន់ធ្ងរអាចកើតឡើងក៏ដោយ តែផលប៉ះពាល់ទាំងនោះកម្រនឹងកើតឡើងណាស់។ អត្ថប្រយោជន៍នៃការធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 នៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលា គឺមានច្រើនជាងហានិភ័យផ្សេងៗ។**

**ជំនឿតៗគ្នា #2៖ យើងមិនដឹងគ្រប់គ្រាន់អំពីផលប៉ះពាល់រយៈពេលវែងនៃថ្នាំបង្ការទាំងនេះទេ។**

**ការពិត៖ ការយល់ដឹងផ្នែកវិទ្យាសាស្ត្រអំពីដំណើរការនៃថ្នាំបង្ការបង្ហាញប្រាប់យើងថា ថ្នាំបង្ការជំងឺ COVID-19 ស្ទើរតែមិនអាចបង្កឱ្យមានផលប៉ះពាល់រយៈពេលវែងនោះទេ។**

ផ្អែកទៅលើអ្វីដែលយើងដឹងអំពីថ្នាំបង្ការផ្សេងទៀត ផលប៉ះពាល់រយៈពេលវែងផ្សេងៗលេចចេញឡើងក្នុងអំឡុងពេលប្រាំមួយសប្តាហ៍បន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការ។ ចំពោះហេតុផលនេះ រដ្ឋបាលចំណីអាហារនិងឱសថ (FDA) បានតម្រូវចាំបាច់ឱ្យក្រុមហ៊ុនផលិតថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ តាមដានអ្នកចូលរួមក្នុងការសាកល្បងយ៉ាងហោចណាស់រយៈពេលប្រាំបីសប្តាហ៍។ លើសពីនេះទៀត មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) បន្តតាមដានថ្នាំបង្ការជំងឺ COVID-19 យ៉ាងជិតដល់បន្ទាប់ពីថ្នាំបង្ការទាំងនោះបានទទួលការអនុញ្ញាត ឬការអនុម័តឱ្យប្រើប្រាស់ និងខណៈមនុស្សកាន់តែច្រើនឡើងៗបានទទួលថ្នាំបង្ការ។ មានរយៈពេលច្រើនជាងមួយឆ្នាំហើយ ចាប់តាំងពីពេលដែលថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ (ហើយច្រើនជាងពីរឆ្នាំហើយ ចាប់តាំងពីការធ្វើតេស្តសាកល្បង

ថ្នាំបង្ការនេះ)។ មនុស្សរាប់ពាន់លាននាក់បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ហើយមិនមានការកត់សម្គាល់ថាមានផលប៉ះពាល់រយៈពេលវែងណាមួយដែលមិននឹកស្មានដល់នោះទេ។

ផ្ទុយទៅវិញ យើងពិតជាដឹងថាមេរោគដែលបង្កឱ្យមានជំងឺ COVID-19 អាចបណ្តាលឱ្យមានផលប៉ះពាល់រយៈពេលវែងជាច្រើនទាំងចំពោះមនុស្សពេញវ័យ និងចំពោះកុមារ។ ឧទាហរណ៍ មនុស្សមួយចំនួនបន្តមានរោគសញ្ញានានា ដូចជាមានអារម្មណ៍នឿយហត់ខ្លាំង ពិបាកក្នុងការគេង ឈឺក្បាល និងដកដង្ហើមខ្លីៗ អស់រយៈពេលជាច្រើនខែ បន្ទាប់ពីការឆ្លងជំងឺ COVID-19 លើកដំបូងរបស់ពួកគេ ដែលជាទូទៅត្រូវបានហៅថាជំងឺ COVID-19 រយៈពេលយូរ (long COVID)។ លើសពីនេះទៅទៀត ស្ថានភាពធ្ងន់ធ្ងរមួយដែលហៅថា រោគសញ្ញានៃការរលាកពហុសរីរាង្គ (Multi-System Inflammatory Syndrome) អាចប៉ះពាល់ដល់កុមារ (MIS-C) និងមនុស្សពេញវ័យ (MIS-A) ផងដែរ។ រោគសញ្ញា MIS គឺជាស្ថានភាពសុខភាពដ៏កម្រ ប៉ុន្តែធ្ងន់ធ្ងរមួយ ដែលទាក់ទងទៅនឹង COVID-19 ហើយដែលធ្វើឱ្យផ្នែកផ្សេងៗនៃរាងកាយបង្កជាការរលាក រួមទាំងបេះដូង សួត តម្រងនោម ខួរក្បាល ស្បែក ភ្នែក ឬសរីរាង្គក្រពះពោះវៀន ផងដែរ។ អ្នកជំងឺជាច្រើនត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយជាអកុសល អ្នកខ្លះអាចស្លាប់ទៀតផង។ ការចាក់ថ្នាំបង្ការជំងឺ COVID-19 ផ្តល់នូវប្រព័ន្ធការពារប្រឆាំងនឹងផលប៉ះពាល់ "រយៈពេលវែង" នៃមេរោគនេះ។

អ្នកអាចស្វែងយល់បន្ថែមតាមរយៈការចូលទៅកាន់គេហទំព័រ សុវត្ថិភាពនៃថ្នាំបង្ការជំងឺ COVID-19 របស់ CDC។

**ជំនឿតៗគ្នា #3៖ ថ្នាំបង្ការទាំងនោះមានមេរោគដែលបង្កឱ្យមានជំងឺ COVID-19 ហើយអាចធ្វើឱ្យអ្នកធ្លាក់ខ្លួនឈឺបាន។**

**ការពិត៖ មិនមានថ្នាំបង្ការណាមួយមានផ្ទុកមេរោគដែលបណ្តាលឱ្យមានជំងឺ COVID-19 នោះទេ។ ថ្នាំបង្ការមិនអាចបង្កឱ្យមានជំងឺ COVID-19 ឡើយ។**

ប្រសិនបើអ្នកឆ្លងជំងឺ COVID-19 ភ្លាមបន្ទាប់ពីការទទួលចាក់ថ្នាំបង្ការ នោះគឺដោយសារតែអ្នកបានឆ្លងពីមនុស្សដែលមានជំងឺ COVID-19 នៅក្នុងអំឡុងពេលប្រហាក់ប្រហែលគ្នាជាមួយនឹងពេលដែលអ្នកបានចាក់ថ្នាំបង្ការ។ អាចត្រូវការពេលរហូតដល់ 10 ថ្ងៃដើម្បីឱ្យរោគសញ្ញានានាបង្ហាញចេញមក បន្ទាប់ពីអ្នកបានឆ្លងមេរោគ។ ដូច្នេះ ប្រសិនបើអ្នកឆ្លងមេរោគភ្លាមៗមុនពេលចាក់ថ្នាំបង្ការ អ្នកប្រហែលជាមិនធ្លាក់ខ្លួនឈឺទេ រហូតដល់ក្រោយពេលអ្នកចាក់ថ្នាំបង្ការរបស់អ្នកហើយ។

ជួនកាលមនុស្សមានអាការៈគ្រុនក្តៅ ឬអស់កម្លាំងប្រមាណមួយឬពីរថ្ងៃបន្ទាប់ពីការចាក់ថ្នាំបង្ការ។ អាការៈទាំងនេះគឺជាផលប៉ះពាល់ជាធម្មតានៃថ្នាំបង្ការ ពីព្រោះរាងកាយកំពុងកសាងភាពស៊ាំ ហើយមិនមែនជាជំងឺដែលបណ្តាលមកពីមេរោគនោះទេ។ អាការៈទាំងនេះមិនមានរយៈពេលយូរទេ ហើយនឹងបាត់ទៅវិញក្នុងរយៈពេលពីរទៅបីថ្ងៃក្រោយ។

**ជំនឿតៗគ្នា #4 នៅពេលដែលនរណាម្នាក់ចាក់ថ្នាំបង្ការជំងឺ COVID-19 ថ្នាំបង្ការនោះបណ្តាលឱ្យពួកគេបញ្ចេញមេរោគ COVID-19 មកក្រៅ និងចម្លងទៅកាន់មនុស្សដែលនៅក្បែរ។**

**ការពិត៖ មិនមានថ្នាំបង្ការណាមួយក្នុងចំណោមថ្នាំបង្ការទាំងបួនប្រភេទ ដែលបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក មានផ្ទុកមេរោគ COVID-19 ឡើយ ទោះជាក្នុងទម្រង់ណាមួយក៏ដោយ។ ការទទួលចាក់ថ្នាំបង្ការមិនអាចបណ្តាលឱ្យអ្នកបញ្ចេញមេរោគមកក្រៅបានទេ។**

មិនមានវិធីណាមួយទេដែលថាថ្នាំបង្ការជំងឺ COVID-19 អាចចម្លងមេរោគដែលបណ្តាលឱ្យមានជំងឺ COVID-19 ទៅនរណាម្នាក់ ឬធ្វើឱ្យពួកគេអាចចម្លងមេរោគបន្តនោះទេ។ ការបញ្ចេញមេរោគមកក្រៅដោយការចាក់ថ្នាំបង្ការ អាចកើតមានឡើងតែនៅពេលដែលថ្នាំបង្ការមួយ មានផ្ទុកប្រភេទមេរោគដែលបានធ្វើឱ្យមានភាពទន់ខ្សោយប៉ុណ្ណោះ។ មិនមានថ្នាំបង្ការណាមួយក្នុងចំណោមថ្នាំបង្ការទាំងបួនប្រភេទ ដែលបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក មានផ្ទុកមេរោគ COVID-19 ឡើយ ទោះក្នុងទម្រង់ណាមួយក៏ដោយ។ ថ្នាំបង្ការទាំងនេះមិនមានមេរោគសម្រាប់បញ្ចេញមកក្រៅឡើយ។

**ជំនឿតៗគ្នា #5៖ ថ្នាំបង្ការទាំងនេះប្រើប្រាស់សារធាតុហ្សែន (genetic material) ដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគ។ នោះមានន័យថា ថ្នាំបង្ការទាំងនេះអាចប៉ះពាល់ដល់ហ្សែន (genes) របស់យើង។**

**ការពិត៖ ថ្នាំបង្ការប្រភេទ Novavax មានផ្ទុកខ្មែងជាតិប្រូតេអ៊ីន (spike protein) នៃមេរោគ COVID-19។ ខ្មែងជាតិប្រូតេអ៊ីននេះមិនមានផ្ទុកសារធាតុហ្សែន ឬមេរោគ COVID-19 ទេ។ ថ្នាំបង្ការប្រភេទ Pfizer ប្រភេទ Moderna និង**

**ប្រភេទ J&J ប្រើប្រាស់សារធាតុហ្សែនដែលបង្ហាត់បង្រៀនរាងកាយរបស់អ្នកអំពីរបៀបប្រយុទ្ធប្រឆាំងនឹងមេរោគ។ ប៉ុន្តែសារធាតុហ្សែននេះមិនផ្លាស់ប្តូរហ្សែនផ្ទាល់របស់អ្នកនោះទេ។**

DNA ឬ RNA នៅក្នុងថ្នាំបង្ការជំងឺ COVID-19 ប្រាប់កោសិកានៃរាងកាយរបស់យើង អំពីរបៀបផលិតបំណែកនៃខ្ទែងជាតិប្រូតេអ៊ីនដែលបានរកឃើញនៅលើមេរោគ COVID-19។ ជំហាននេះគឺចាំបាច់សម្រាប់ប្រព័ន្ធភាពស៊ាំរាងកាយរបស់យើង ដើម្បីបង្កើតការឆ្លើយតបទប់ទល់នឹងមេរោគ។ បន្ទាប់មក ប្រព័ន្ធភាពស៊ាំបង្កើតសារធាតុទប់ទល់នឹងជំងឺ ឬអង់ទីក័រ (antibodies) និងរៀបចំកោសិកាភាពស៊ាំដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគ COVID-19 ប្រសិនបើយើងបានប៉ះពាល់ទៅនឹងមេរោគនេះ នាពេលអនាគត។

ថ្នាំបង្ការប្រភេទ Pfizer និងប្រភេទ Moderna មានផ្ទុក mRNA (ជាភ្នាក់ងារផ្តល់ព័ត៌មាន RNA)។ mRNA មិនដែលចូលទៅក្នុងស្នូលកោសិកាដែលជាទីតាំង DNA របស់យើងឡើយ ដូច្នេះភ្នាក់ងារនេះមិនអាចផ្លាស់ប្តូរ DNA របស់យើងទេ។ ថ្នាំបង្ការប្រភេទ J&J គឺជាប្រភេទថ្នាំបង្ការដែលមានមេរោគទូទៅ (adenovirus) ដែលមានផ្ទុក DNA នៅក្នុងនោះ។ ថ្នាំបង្ការដែលមានមេរោគទូទៅ ប្រើប្រាស់មេរោគដែលបានធ្វើការផ្លាស់ប្តូរ ដូច្នេះមេរោគនេះមិនអាចធ្វើឱ្យយើងធ្លាក់ខ្លួនឈឺទេ ហើយមេរោគនេះមិនអាចថតចម្លងខ្លួនបានដែរ។ DNA នៅក្នុងថ្នាំបង្ការមិនអាចផ្សំជាមួយ DNA (ឬក៏ក្រូម៉ូសូម/chromosomes) របស់យើងនោះទេ ពីព្រោះថ្នាំបង្ការមិនមានសារធាតុអង់ស៊ីម (ហៅថាការរួមបញ្ចូល) ដែលតភ្ជាប់ DNA ចូលគ្នានោះទេ។

**ជំនឿតៗគ្នា #6៖ ថ្នាំបង្ការទាំងឡាយមានផ្ទុកមីក្រូឈីប (microchip) ដែលត្រូវបានប្រើប្រាស់ដើម្បីតាមដានសកម្មភាពរបស់ខ្ញុំ។**

**ការពិត៖ មិនមានមីក្រូឈីប ឬក៏ឧបករណ៍តាមដានខ្នាតតូច ប្រភេទណាមួយ នៅក្នុងថ្នាំបង្ការជំងឺ COVID-19 ទេ។**

ម្ជុលដែលមានការប្រើប្រាស់ដើម្បីចាក់ថ្នាំបង្ការជំងឺ COVID-19 មានទំហំតូចជាងទំហំមីក្រូឈីប ដែលតូចបំផុតទៅទៀត។ ជំនឿតៗគ្នាទាំងនេះបានចាប់ផ្តើមនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយអះអាងថាសហស្ថាបនិកក្រុមហ៊ុន Microsoft លោក Bill Gates ចង់តាមដានមនុស្សដោយដាក់បញ្ចូលមីក្រូឈីបទៅក្នុងខ្លួនពួកគេ។ មូលនិធិ Bill និង Melinda Gates (Bill and Melinda Gates Foundation) បានបញ្ជាក់ដោយមានកំណត់ត្រាថា នេះជាការអះអាង មិនពិត។ ដូចនឹងជំនឿតៗគ្នាដែលមាននៅតាមប្រព័ន្ធអនឡាញជាច្រើន នេះគឺជារឿងដែលពិបាកក្នុងការបញ្ឈប់ សូម្បីតែបន្ទាប់ពីមានការបញ្ជាក់ថាជារឿងមិនពិតម្តងហើយម្តងទៀតក៏ដោយ។

**ជំនឿតៗគ្នា #7៖ ម្ជុលនៅជាប់នៅក្នុងដើមដៃរបស់អ្នក បន្ទាប់ពីអ្នកបានទទួលចាក់ថ្នាំបង្ការរួច។**

**ការពិត៖ ម្ជុលមិននៅជាប់នៅក្នុងដើមដៃរបស់អ្នកបន្ទាប់ពីអ្នកបានចាក់ថ្នាំបង្ការរួចទេ។ ម្ជុល "បាត់" ពីព្រោះម្ជុលនោះលិបចូលទៅក្នុងសឺរ៉ាំង ឬប្រអប់សុវត្ថិភាពបន្ទាប់ពីចាក់រួច។**

អ្នកប្រហែលជាបានឃើញវីដេអូដែលបង្ហាញថាម្ជុលរក្សានៅជាប់នឹងក្នុងដើមដៃមនុស្សបន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការរួចហើយ។ អ្វីដែលអ្នកកំពុងឃើញ គឺម្ជុលដែលអាចលិបចូល កំពុងដំណើរការ។ សឺរ៉ាំងដែលមានម្ជុលអាចលិបចូលបានដំណើរការដោយទាញម្ជុលចូលទៅក្នុងបំពង់សឺរ៉ាំង ឬចូលទៅក្នុងប្រអប់សុវត្ថិភាពនៅផ្នែកម្ខាងនៃសឺរ៉ាំង បន្ទាប់ពីការចាក់ថ្នាំបង្ការរួចរាល់។ បុគ្គលិកថែទាំសុខភាពប្រើប្រាស់សឺរ៉ាំងប្រភេទទាំងនេះ ដើម្បីជៀសវាងការចាក់មុតដោយម្ជុល។

ម្ជុលដែលប្រើប្រាស់សម្រាប់ថ្នាំបង្ការជំងឺ COVID-19 គឺស្តើងណាស់ ហើយបរិមាណថ្នាំបង្ការក៏តិចតួចដែរ។ ដោយសារទាំងម្ជុលនិងបរិមាណដូសតូចនោះ ទើបអ្នកប្រហែលជាអាចមិនមានអារម្មណ៍ថាមានការចាក់ម្ជុល ឬថ្នាំបង្ការចូលទៅក្នុងដើមដៃរបស់អ្នកទេ។ មុនពេលដែលអ្នកចាក់ថ្នាំបង្ការ អ្នកអាចឃើញសារធាតុរាវថ្លានៅខាងក្នុងសឺរ៉ាំង និងម្ជុលនៅខាងចុង។ បន្ទាប់ពីការចាក់ថ្នាំបង្ការ អ្នកនឹងឃើញថាមិនមានសារធាតុរាវនៅសល់ទៀតឡើយ ហើយម្ជុលគឺនៅខាងក្នុងបំពង់ (ឬប្រអប់សុវត្ថិភាព)។

**ជំនឿតៗគ្នា #8៖ "ការធ្វើតេស្តមេដែក" គឺជាភស្តុតាងដែលបង្ហាញថាមានមីក្រូឈីប (microchip) ឬម្ជុលដែលបន្សល់ទុកនៅជាប់ក្នុងដើមដៃរបស់អ្នក បន្ទាប់ពីអ្នកបានទទួលចាក់ថ្នាំបង្ការរួច។**

**ការពិត៖ ការធ្វើបែបនេះគ្រាន់តែជាល្បិចមួយ ដែលត្រូវបានប្រើប្រាស់ដើម្បីបោកបញ្ឆោតអ្នកប៉ុណ្ណោះ។**

មានវីដេអូនៅលើបណ្ដាញសង្គមជាច្រើនបង្ហាញពីមេដែកដែលជាប់នឹងដើមដៃរបស់មនុស្ស តាមទីតាំងដែលពួកគេបានចាក់ថ្នាំបង្ការ។ នេះគឺដើម្បីព្យាយាមបង្ហាញថា ថ្នាំបង្ការមានមីក្រូឈីប ឬបង្ហាញថាមានម្ជុលដែលបន្សល់ទុកឱ្យនៅជាប់ចោល។ នេះគឺគ្រាន់តែជាល្បិចមួយប៉ុណ្ណោះ។

មេដែកអាចធ្វើឱ្យជាប់ទៅនឹងស្បែកបានយ៉ាងងាយស្រួលបំផុត ដោយប្រើប្រាស់បង់ស្អិតបិទ ឬថ្នាំលាបស្អិត។ សូម្បីតែការចុចមេដែក ឬកាក់ឱ្យខ្លាំងទៅនឹងស្បែករបស់អ្នក ក៏អាចធ្វើអាចធ្វើឱ្យមេដែក ឬកាក់នោះជាប់បានហើយ។ លើសពីនេះទៅទៀត បរិមាណលោហៈដែលត្រូវការដើម្បីឱ្យមេដែកអាចទាញបាននោះ នឹងមានទំហំធំពេកដើម្បីដាក់ចូលក្នុងម្ជុលដែលប្រើប្រាស់ក្នុងការចាក់ថ្នាំបង្ការជំងឺ COVID-19 នេះ។

**ជំនឿតៗគ្នា #9៖ អ្នកមិនអាចជឿទុកចិត្តលើអ្នកដែលផលិតថ្នាំបង្ការទាំងនេះទេ។ "ក្រុមហ៊ុនថ្នាំពេទ្យធំៗ" ឬ "Big Pharma" គឺគ្រាន់តែចង់រកលុយ ហើយចំណាយប្រាក់ឱ្យគ្រូពេទ្យដើម្បីឱ្យពួកគេនិយាយថាផលិតផលរបស់ខ្លួនមានសុវត្ថិភាពតែប៉ុណ្ណោះ។**

**ការពិត៖ ដំណើរការនៃការបង្កើតថ្នាំបង្ការទាំងនេះមិនមានភាពលាក់បាំងទេ។ មានផ្ដល់ជូនព័ត៌មាននិងទិន្នន័យបន្ថែមឱ្យអ្នកវិទ្យាសាស្ត្រឯករាជ្យ និងសាធារណជនច្រើនជាងពេលណាៗទាំងអស់។**

ខណៈពេលដែលមានឧទាហរណ៍ដ៏គួរឱ្យអាក្រក់ជាច្រើន នៃក្រុមហ៊ុនផលិតថ្នាំពេទ្យដែលគិតប្រាក់ចំណេញជាងគិតពីសុវត្ថិភាពនោះ ការបង្កើតថ្នាំបង្ការទាំងនេះត្រូវបានធ្វើឡើងក្រោមការតាមដានពីក្រសែភ្នែកសាធារណជន។ ការពិនិត្យឡើងវិញអំពីសុវត្ថិភាព និងប្រសិទ្ធិភាពនៃថ្នាំបង្ការ (efficacy) (ជាពាក្យដែលប្រើប្រាស់ដើម្បីមានន័យថាថ្នាំបង្ការមានដំណើរការល្អ) ត្រូវបានបោះពុម្ពផ្សាយសម្រាប់មនុស្សគ្រប់រូបដើម្បីអានបាន។

ក្រុមអ្នកដែលពិនិត្យមើលការស្រាវជ្រាវនេះ រួមមានអ្នកដឹកនាំផ្នែកវេជ្ជសាស្ត្រមកពីសាវតារផ្សេងៗគ្នាទូទាំងប្រទេស។ ពួកគេតំណាងឱ្យក្រុមវេជ្ជសាស្ត្រជាច្រើន រួមទាំងក្រុមខ្លះដែលបានតស៊ូប្រឆាំងនឹងការរើសអើងជាតិសាសន៍ទាក់ទងនឹងផ្នែកវេជ្ជសាស្ត្រផងដែរ។ ពួកគេមិនបានទទួលប្រាក់ចំពោះការបំពេញការងារនេះទេ ហើយចូលរួមក្នុងការផ្ទៀងផ្ទាត់គុណភាពនៃការស្រាវជ្រាវ និងដើម្បីធានាថាបានការពារសមធម៌ក្នុងពេលដំណើរការនេះ។ សម្រាប់តារាងបញ្ជីឈ្មោះរបស់អ្នកត្រួតពិនិត្យ និងទីកន្លែងដែលពួកគេធ្វើការ សូមចូលមើល គេហទំព័រ របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ដីពីការអនុវត្តការចាក់ថ្នាំបង្ការ (ACIP)។ អ្នកអាចស្វែងយល់បន្ថែមអំពីអ្នកទាំងនេះដោយស្វែងរកពួកគេតាមប្រព័ន្ធអនឡាញបាន។ អ្នកក៏អាចមើលការប្រជុំរបស់ ACIP មួយចំនួនតាមប្រព័ន្ធអនឡាញបានផងដែរ។

**ជំនឿតៗគ្នា #10៖ សហគមន៍ជនជាតិស្បែកខ្មៅ និងជនជាតិអាមេរិកឡាទីន គឺជាក្រុមតែពីរគត់ដែលមានការជ្រើសរើសក្នុងចំណោមក្រុមដទៃទៀត ដើម្បីទទួលចាក់ថ្នាំបង្ការ ពីព្រោះមិនមានភ័ស្តុតាងពិតប្រាកដទេ ដែលថាថ្នាំបង្ការមានសុវត្ថិភាពនោះ។**

**ការពិត៖ សហគមន៍ជនជាតិស្បែកខ្មៅ និងជនជាតិអាមេរិកឡាទីន មិនមែនជាក្រុមតែពីរគត់ដែលមានការជ្រើសរើសក្នុងចំណោមក្រុមដទៃទៀត ក្នុងផ្លូវមិនល្អនោះទេ។ ប៉ុន្តែមានការជំរុញឱ្យពួកគេទទួលចាក់ថ្នាំបង្ការនេះ ដោយសារតែពួកគេមានអត្រានៃការឆ្លងមេរោគ ការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ដោយសារជំងឺ COVID-19 ខ្ពស់ជាងក្រុមផ្សេងទៀត។**

ការព្រួយបារម្ភនេះគឺអាចយល់បាន។ កាលពីពេលកន្លងទៅ មនុស្សដែលមានពណ៌សម្បុរផ្សេងៗ បានទទួលពាក្យកុហក ឬការបង្ខំឱ្យធ្វើតេស្តថ្នាំពេទ្យ ឬនីតិវិធីវេជ្ជសាស្ត្រក្រោមការអនុវត្តន៍ខុសក្រមសីលធម៌ ដែលធ្វើឱ្យសុខភាពពួកគេប្រឈមនឹងហានិភ័យ។

ថ្នាំបង្ការដែលមានផ្ដល់ជូននៅក្នុងសហរដ្ឋអាមេរិក ត្រូវបានសាកល្បងលើប្រជាជនចំរុះក្រុម។ មានការខិតខំប្រឹងប្រែងដើម្បីរួមបញ្ចូលអ្នកស្ម័គ្រចិត្តជនជាតិស្បែកខ្មៅ និងជនជាតិអាមេរិកឡាទីនឱ្យមានគ្រប់ចំនួនមនុស្សដែលអាចឆ្លុះបញ្ចាំងពីចំនួនប្រជាជនទាំងអស់ផងដែរ។ ការធ្វើបែបនេះគឺដើម្បីឱ្យប្រាកដថា ថ្នាំបង្ការមានសុវត្ថិភាពនិងមានប្រសិទ្ធិភាពសម្រាប់ក្រុមមនុស្សទាំងនោះ។ ការធ្វើបែបនេះក៏ដើម្បីការពារក្រុមទាំងនេះពីការក្លាយជាជនរងគ្រោះនៃការធ្វេសប្រហែសខាងវេជ្ជសាស្ត្រ ឬការរើសអើងជាតិសាសន៍ផងដែរ។

គ្រូពេទ្យ និងកម្មវិធីសុខភាពសាធារណៈទាំងឡាយខិតខំប្រឹងប្រែង ដើម្បីឱ្យប្រាកដថាសហគមន៍ជនជាតិស្បែកខ្មៅ និងជនជាតិអាមេរិកឡាទីនទទួលបានថ្នាំបង្ការជំងឺ COVID-19 ស្មើគ្នា។ ប្រជាជនស្បែកខ្មៅ និងប្រជាជនអាមេរិកឡាទីន ក៏

ដូចជាជនជាតិដើមអាមេរិកាំង និងជនជាតិដើមកោះហាវៃ ជួបប្រទះនូវអត្រានៃការឆ្លងមេរោគ ការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ដោយសារជំងឺ COVID-19 ខ្ពស់បំផុត។ នេះជាមូលហេតុដែលអ្នកអាចឃើញផ្ទាំងរូបភាពផ្សាយពាណិជ្ជកម្មធំៗ ឬការផ្សាយពាណិជ្ជកម្មផ្សេងៗជំរុញឱ្យសហគមន៍ទាំងនេះទទួលចាក់ថ្នាំបង្ការ។

ខោនធី LA ចង់ឱ្យសហគមន៍ដែលបានរងគ្រោះខ្លាំងជាងគេទាំងនេះ មានឱកាសទទួលចាក់ថ្នាំបង្ការឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។ ប្រជាជនស្បែកខ្មៅ និងប្រជាជនអាមេរិកឡាទីនប្រឈមនឹងបញ្ហាខ្ពស់។ សូមអានអ្វីដែលអ្នកអាចអានបាន ទាក់ទងនឹងថ្នាំបង្ការ ពីប្រភពដែលអាចទុកចិត្តបាន។ ចូរពិគ្រោះជាមួយនឹងមនុស្សដែលមានចំណេះដឹងល្អហើយអ្នកទុកចិត្តបាន ដូចជាគ្រូពេទ្យ គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ ឬឱសថការី (អ្នកលក់ថ្នាំពេទ្យ) ហើយសួរពួកគេអំពីសំណួរ និងក្តីកង្វល់របស់អ្នក។ សំណួររបស់អ្នកគឺសំខាន់ ហើយសមនឹងទទួលបានចម្លើយពីបុគ្គលដែលមានចំណេះដឹងនិងអាចទុកចិត្តបាន។

**ជំនឿតៗគ្នា #11៖ ខ្ញុំមិនត្រូវការថ្នាំបង្ការទេ ប្រសិនបើខ្ញុំធ្លាប់មានជំងឺ COVID-19 រួចហើយនោះ។**

**ការពិត៖ គ្រូពេទ្យ និងអ្នកវិទ្យាសាស្ត្រទាំងឡាយ ណែនាំឱ្យមនុស្សគ្រប់គ្នាធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេ នៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលា បើទោះបីជាអ្នកធ្លាប់មានជំងឺ COVID-19 រួចហើយក៏ដោយ។**

ប្រព័ន្ធភាពស៊ាំធម្មជាតិគឺជាប្រព័ន្ធការពារដែលអ្នកទទួលបានបន្ទាប់ពីអ្នកធ្លាប់មានជំងឺ COVID-19 រួចហើយនោះ។ ប្រព័ន្ធការពារនេះអាចនឹងមិនស្ថិតស្ថេរទេ ហើយអ្នកអាចឆ្លងជំងឺ COVID-19 ម្តងទៀត។ ការទទួលចាក់ថ្នាំបង្ការ រួមទាំងដូសជំរុញនៅពេលដល់កំណត់អាចទទួលបាននោះ នឹងជួយបង្កើតភាពស៊ាំរបស់អ្នកដើម្បីផ្តល់នូវប្រព័ន្ធការពារកាន់តែប្រសើរ និងយូរអង្វែងជាងមុន ប្រឆាំងនឹងជំងឺ COVID-19។ ការទទួលចាក់ថ្នាំបង្ការកាត់បន្ថយហានិភ័យរបស់អ្នកចំពោះការឆ្លងមេរោគឡើងវិញ។ ប្រសិនបើអ្នកពិតជាឆ្លងមេរោគម្តងទៀត ថ្នាំបង្ការជួយកាត់បន្ថយហានិភ័យនៃការកើតជំងឺកម្រិតធ្ងន់ធ្ងរ ការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ដោយសារជំងឺ COVID-19 ផងដែរ។

**ជំនឿតៗគ្នា #12៖ ថ្នាំបង្ការជំងឺ COVID-19 មានផ្ទុកកោសិកាទារកដែលបានរំលូត។ ខ្ញុំមិនឯកភាពចំពោះការរំលូតកូនទេ។ ការចាក់ថ្នាំបង្ការគឺមិនត្រឹមត្រូវទេ ពីព្រោះថ្នាំបង្ការទាំងឡាយមានកោសិកាទារកដែលបានរំលូត។**

**ការពិត៖ មិនមានថ្នាំបង្ការណាមួយដែលបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក មានផ្ទុកជាលិកាទារក ឬកោសិកាទារកឡើយ។**

មានការប្រើប្រាស់បណ្តាញកោសិកាទារកដែលបានផលិតឡើងនៅក្នុងមន្ទីរពិសោធន៍ ដោយបានមកពីកោសិកានៃការរំលូតកូនចំនួន 2 លើកនៅក្នុងឆ្នាំ 1973 និងឆ្នាំ 1985 ក្នុងការបង្កើត ការធ្វើតេស្ត ឬការផលិតថ្នាំបង្ការ COVID-19។ កោសិកាទារកដែលបានប្រើប្រាស់នោះ គឺមិនមែនបានមកពីការពន្លូតកូននាពេលថ្មីៗនេះ ឬពីការរំលូតកូនដែលបានធ្វើឡើងក្នុងគោលបំណងដើម្បីការបង្កើតថ្នាំបង្ការតែមួយគត់នោះទេ។

- **ក្រុមហ៊ុន Pfizer និងក្រុមហ៊ុន Moderna** មិនបានប្រើប្រាស់បណ្តាញកោសិកាទារកដើម្បីបង្កើត ឬផលិតថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេទេ។ ពួកគេពិតជាបានប្រើប្រាស់បណ្តាញកោសិកាទារកសម្រាប់ការធ្វើតេស្តនៅមន្ទីរពិសោធន៍ មុនពេលការធ្វើតេស្តថ្នាំបង្ការរបស់ពួកគេទៅលើមនុស្ស។
- **ក្រុមហ៊ុន Johnson & Johnson** បានប្រើប្រាស់បណ្តាញកោសិកាទារកដើម្បីបង្កើត និងធ្វើតេស្តសាកល្បងថ្នាំបង្ការ COVID-19 របស់ពួកគេ។ ពួកគេក៏ប្រើប្រាស់បណ្តាញកោសិកាទារកសម្រាប់ផលិតកម្មថ្នាំបង្ការផងដែរ។
- **ក្រុមហ៊ុន Novavax មិនបានប្រើប្រាស់បណ្តាញកោសិកាទារកដើម្បីបង្កើត ឬធ្វើតេស្តថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេទេ។**

ព្រះវិហារកាតូលិកបានពិនិត្យមើលឡើងវិញនូវការប្រើប្រាស់កោសិកាទារក ក្នុងគោលបំណងនៃការផលិតថ្នាំបង្ការជំងឺ COVID-19 នេះ។ ពួកគេបានបញ្ជាក់ថា "ការទទួលថ្នាំបង្ការជំងឺ COVID-19 ដែលប្រើប្រាស់បណ្តាញកោសិកាពីទារកដែលបានរំលូតសម្រាប់ ដំណើរការស្រាវជ្រាវ និងដំណើរការផលិតកម្មរបស់ពួកគេ គឺអាចទទួលយកបានតាមក្រមសីលធម៌"។

ប្រសិនបើបញ្ហានេះធ្វើឱ្យអ្នកមានការព្រួយបារម្ភ អ្នកអាចនឹងចង់ពិនិត្យមើលឡើងវិញនូវឯកសារ [ថ្នាំបង្ការជំងឺ COVID-19 និងបណ្តាញកោសិកាទារក] ដោយយកចិត្តទុកដាក់ ដូច្នេះអ្នកអាចធ្វើការសម្រេចចិត្តអំពីការទទួលចាក់ថ្នាំបង្ការបាន។

**ជំនឿតៗគ្នា #13៖ យើងមិនដឹងថា តើមានអ្វីខ្លះនៅក្នុងថ្នាំបង្ការជំងឺ COVID-19 នោះទេ។**

**ការពិត៖ គ្រឿងផ្សំទាំងឡាយរបស់ថ្នាំបង្ការមានផ្តល់ជូនមនុស្សគ្រប់គ្នាសម្រាប់ការពិនិត្យមើលបាន។**

គ្រឿងផ្សំទាំងឡាយនៅក្នុងថ្នាំបង្ការទាំង 4 ប្រភេទដែលមានឱ្យប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក មានភាពខុសគ្នា អាស្រ័យទៅតាមក្រុមហ៊ុនផលិត។ ស្វែងយល់បន្ថែមថាគ្រឿងផ្សំគឺជាអ្វី និងមិនមែនជាអ្វី នៅក្នុងថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ប្រភេទ Moderna ប្រភេទ Novavax និង ប្រភេទ Johnson & Johnson។

ក្រៅពីសារធាតុហ្សែន (genetic material) ឬសារធាតុប្រូតេអ៊ីនដែលបានប្រើប្រាស់ ដើម្បីជំរុញប្រព័ន្ធភាពស៊ាំរបស់អ្នក គ្រឿងផ្សំទាំងឡាយគឺជម្មតាទូទៅ។ គ្រឿងផ្សំមួយចំនួនមានឈ្មោះជាលក្ខណៈវិទ្យាសាស្ត្រគីមី ប៉ុន្តែប្រសិនបើអ្នកពិនិត្យមើលបន្ថែម អ្នកនឹងឃើញថា គ្រឿងផ្សំស្ទើរតែទាំងអស់នៅក្នុងថ្នាំបង្ការជំងឺ COVID-19 អាចរកឃើញនៅក្នុងអាហារជាច្រើន។ គ្រឿងផ្សំទាំងនេះមានសុវត្ថិភាព លុះត្រាតែអ្នកមានប្រតិកម្ម ឬការទាស់ទៅនឹងគ្រឿងផ្សំណាមួយ។

មិនមានថ្នាំបង្ការណាមួយដែលមានឱ្យប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិកមានផ្ទុកសារធាតុប្រូតេអ៊ីនអាហារ (ដូចជាស៊ុត ឬផលិតផលគ្រាប់ធញ្ញជាតិ) ជ័រកៅស៊ូ ថ្នាំប្រឆាំងមេរោគ (antibiotics) ថ្នាំពេទ្យផ្សេងទៀត សារធាតុគីមីទុកកុំឱ្យខូច (ដូចជាសារធាតុទប់ស្កាត់ការដុះផ្សិត [thimerosal] ឬជាតិបារត [mercury]) ឬក៏ជាលិកា (ដូចជាកោសិកាទារកដែលបានរំលូត ឬវត្ថុធាតុដើមណាមួយពីសត្វ) ឡើយ។ គ្រឿងផ្សំទាំងឡាយមិនមានលោហៈណាមួយ ដូចជាដែក នីកែល (nickel) កូបាលីច (cobalt) លីចូម (lithium) និងលោហធាតុផ្សំប្រភេទកម្រផ្សេងៗ (rare earth alloys) ឡើយ។ ថ្នាំបង្ការទាំងឡាយក៏មិនមានផ្ទុកផលិតផលដែលបានបង្កើតឡើង ដូចជាគ្រឿងអេឡិចត្រូនិចល្អិត (microelectronics) វត្ថុចម្លងអគ្គិសនី (electrodes) បំពង់ទីបល្អិតមានជាតិកាបោន (carbon nanotubes) ឬវត្ថុចម្លងពាក់កណ្តាលដែលមានខ្សែល្អិត (nanowire semiconductors) ឡើយ។

**ជំនឿតៗគ្នា #14៖ កម្មវិធី VAERS ដែលជាប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍អវិជ្ជមាននៃថ្នាំបង្ការ (Vaccine Adverse Event Reporting System) បានបង្ហាញថា មនុស្សរាប់ពាន់នាក់ រួមទាំងកុមារផងដែរ បានស្លាប់ដោយសារថ្នាំបង្ការជំងឺ COVID-19។**

**ការពិត៖ របាយការណ៍របស់កម្មវិធី VAERS តែមួយគត់ មិនអាច និងមិនគួរមានការប្រើប្រាស់ដើម្បីកំណត់ថា តើថ្នាំបង្ការបង្កឱ្យមានព្រឹត្តិការណ៍អវិជ្ជមានឬនោះទេ។ ព្រឹត្តិការណ៍អវិជ្ជមានកម្រិតធ្ងន់ធ្ងរទាំងឡាយ អាចនឹងកើតមានបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ប៉ុន្តែកម្រនឹងកើតមាន។ មិនមានការបញ្ជាក់ច្បាស់លាស់អំពីការស្លាប់ចំពោះកុមារដែលបណ្តាលមកពីថ្នាំបង្ការជំងឺ COVID-19 នោះទេ។ ផ្ទុយទៅវិញ គិតត្រឹមថ្ងៃទី 1 ខែសីហា ឆ្នាំ 2022 មានកុមារជាង 1,700 នាក់បានស្លាប់ដោយសារការឆ្លងជំងឺ COVID-19។**

មានការភាន់ច្រឡំអំពីចំនួនអ្នកស្លាប់ដែលបានរាយការណ៍នៅក្នុងទិន្នន័យដែលអាចរកបានជាសាធារណៈពីកម្មវិធី VAERS។ ប្រជាជនបានយល់ដឹងដោយខុសអំពីរបាយការណ៍នៃការស្លាប់ដែលទទួលបានពីកម្មវិធី VAERS ថា ជាការស្លាប់ដែលបណ្តាលមកពីថ្នាំបង្ការទៅវិញ។ ចំណុចនោះគឺមិនច្បាស់លាស់ទេ។ កម្មវិធី VAERS ទទួលយករបាយការណ៍ទាំងអស់នៃព្រឹត្តិការណ៍អវិជ្ជមានផ្នែកសុខភាព បន្ទាប់ពីការចាក់ថ្នាំបង្ការ។ បុគ្គលណាក៏អាច ផ្ញើការរាយការណ៍ទៅកម្មវិធី VAERS បានដែរ រួមទាំងសាធារណជនផងដែរ។ ការរាយការណ៍ខ្លះដែលបានបញ្ជូនទៅកម្មវិធី VAERS តំណាងឱ្យប្រតិកម្មពីថ្នាំបង្ការដែលពិតប្រាកដ។ ការរាយការណ៍ផ្សេងទៀត គឺជាព្រឹត្តិការណ៍អវិជ្ជមានផ្នែកសុខភាពដែលកើតមានដោយចៃដន្យ និងមិនទាក់ទងទៅនឹងការចាក់ថ្នាំបង្ការទេ។ ឧទាហរណ៍ ប្រសិនបើមនុស្សម្នាក់បានស្លាប់ក្នុងគ្រោះថ្នាក់មួយប៉ុន្មានថ្ងៃបន្ទាប់ពីទទួលថ្នាំបង្ការ ចំណុចនេះប្រហែលជាអាចត្រូវបានរាយការណ៍ទៅកម្មវិធី VAERS ផងដែរ។ នៅក្នុងប្រព័ន្ធកម្មវិធី VAERS ការស្លាប់នោះនឹងមើលទៅដូចជាព្រឹត្តិការណ៍ដែលទាក់ទងទៅនឹងថ្នាំបង្ការ ពីព្រោះព្រឹត្តិការណ៍នោះបានកើតឡើងភ្លាមៗបន្ទាប់ពីមនុស្សនោះបានទទួលចាក់ថ្នាំបង្ការ បើទោះបីជាមិនមែនជាបញ្ហាដែលបង្កឡើងដោយថ្នាំបង្ការក៏ដោយ។ ការរាយការណ៍ខ្លះអាចមានព័ត៌មានដែលមិនពេញលេញ មិនច្បាស់លាស់ ដោយចៃដន្យ មិនអាចផ្ទៀងផ្ទាត់បាន ឬមិនពិតប្រាកដតែម្តង។

ដើម្បីស្វែងយល់បន្ថែមអំពីដែនកំណត់នៃទិន្នន័យរបស់កម្មវិធី VAERS សូមចូលទៅកាន់ គេហទំព័រកម្មវិធី VAERS របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ឬមើលវីដេអូនៃ កម្មវិធី VAERS និងសុវត្ថិភាពថ្នាំបង្ការ៖ របៀបកម្មវិធីនេះដំណើរការ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីសុវត្ថិភាពថ្នាំបង្ការ សូមចូលទៅកាន់គេហទំព័រស្តីពី សុវត្ថិភាពនៃថ្នាំបង្ការជំងឺ COVID-19 របស់ CDC។

**ឯកសារធនធានបន្ថែម**

សម្រាប់ការលបប់បំបាត់ជំនឿតៗគ្នាផ្សេងទៀត សូមចូលទៅកាន់៖

- *មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)៖* ជំនឿតៗគ្នា និងការពិតអំពីថ្នាំបង្ការជំងឺ COVID-19
- *មន្ទីរពេទ្យកុមារនៃទីក្រុង Philadelphia៖* COVIDVaccineAnswers.org
- *មន្ទីរពេទ្យ Johns Hopkins៖* ថ្នាំបង្ការជំងឺ COVID-19៖ ជំនឿតៗគ្នា ប្រៀបធៀបនឹងការពិត
- *គេហទំព័រ FactCheck.org៖* ការយល់ខុសចំពោះជំងឺ COVID-19

សម្រាប់គន្លឹះផ្សេងៗអំពីរបៀបពិនិត្យមើលព័ត៌មានមិនពិត សូមចូលទៅកាន់៖ *សកលវិទ្យាល័យនៃរដ្ឋ California នៅទីក្រុង San Francisco (UCSF)* ការវាយតម្លៃព័ត៌មានផ្នែកសុខភាព។